# ការការពារទប់ស្កាត់គ្រោះថ្នាក់ចំពោះពលករក្នុងការងារនេសាទ(នាវានេសាទ・ចិញ្ចឹមជលផល)

## សេចក្តីផ្តើម

កូនសៀវភៅនេះ សរសេរណែនាំអំពីប្រការត្រូវប្រុងប្រយ័ត្ន ជៀសវាងបណ្តាលអោយមានរបួស ឬជម្ងឺ ពេលអ្នកកំពុងបំពេញការងារនេសាទ។

ជាមួយនឹងការគោរពការណែនាំរបស់អ្នកត្រួតពិនិត្យ ដូចជានាយនាវាឬប្រធាននេសាទជាដើម, ការធ្វើសកម្មភាពការពារខ្លួនដោយខ្លួនឯង ពិតជាសំខាន់ណាស់។

សូមកុំធ្វេសប្រហែសឬភ្លេចប្រការប្រុងប្រយ័ត្នដែលមានសរសេរនេះ រាល់ពេលកំពុងធ្វើការ។

សូមធ្វើការដោយសុខភាពល្អ, ចុះពីនាវាដោយសុខភាពល្អ និងត្រលប់ទៅជួបជុំគ្រួសារដោយក្តីញញឹម។

※ មានជាភាសាជប៉ុនផងដែរ ប្រសិនបើមានចំនុចណាមិនយល់ សូមសួរបញ្ជាក់ថ្នាក់លើដែលជាជនជាតិជប៉ុន។

## | ការងារនេសាទលើនាវានេសាទ(ការងារលើនាវា។ល។)

### 1. ពេលឡើងនាវា

#### (1) រលកសមុទ្រ និងលំយោលតួនាវា

រលកដោយសារខ្យល់និងរលករីកដាល លាយឡំគ្នាបង្កើតជារលកសមុទ្រ។ ចលនានៃផ្ទៃសមុទ្រនោះគឺស្មុំញ៉ាំ។ រលកសមុទ្រ បុកផ្ទប់នឹងជាន់នាវាពីទិសដៅណាមួយ ចំពេលមិនបានគិតទុក ដែលបណ្តាលអោយនាវិកត្រូវរបួស និងអាចនាំទៅក្នុងសមុទ្រ។

តួនាវាមានចលនាលំយោលស្មុំញ៉ាំ ទៅតាមរលកដោយសារខ្យល់និងរលករីកដាល, ល្បឿននាវានិងការផ្លាស់ប្តូរទិស។

ខុសពីលើគោក, លើនាវាពេលមានលំយោល ហើយរលកសមុទ្រវាយបក់បោកផង, ប្រសិនបើមិនប្រុងប្រយ័ត្នចំពោះជំហ៊ានជើង និងស្ថានភាពជុំវិញទេ នឹងអាចដួលធ្លាក់ចូលសមុទ្រ។

លំយោលនាវានិងរលកសមុទ្រ មិនប្រាកដថាស៊ីសង្វាក់គ្នាទេ។ លំយោលនិងរលកសមុទ្រដែលយើងស្មានមិនដល់ អាចកើតមាន។ នាពេលនោះ ត្រូវស្រមៃគិតទុកជាមុនថាតើត្រូវដោះស្រាយបែបណា។ ចាំបាច់ប្រុងប្រយ័ត្នចំពោះការដែលថា វាមិនមែនជាចលនានៅដដែល ដូចជាទោងបាស់ម្ខាងៗនោះឡើយ។ ការគិតថា「លើកមុនមិនអីលើកនេះក៏មិនអីដែរ」មិនប្រើលើនាវាទេ។

ពេលកំពុងធ្វើការលើជាន់នាវា, ត្រូវប្រុងប្រយ័ត្នដោយមិនត្រូវភ្លេចស្តាប់សញ្ញាប្រកាសអាសន្នពីអ្នកឃ្លាំមើលលើទីខ្ពស់ឬលើជាន់នាវា ដែលកំពុងឃ្លាំមើលរលកសមុទ្រឡើយ។ ជាពិសេសពេលកំពុងនេសាទពេលយប់ ភ្លើងបំភ្លឺដាក់លើជាន់នាវា ធ្វើអោយពិបាកមើលឃើញផ្ទៃសមុទ្រ ដែលជាហេតុចាំបាច់កាន់តែប្រុងប្រយ័ត្នថែមទៀត។ ដាច់ខាតត្រូវពាក់អាវការពារជីវិត ដើម្បីបង្ការការដួលធ្លាក់ក្នុងសមុទ្រ។










- ប្រយ័ត្នក្បាល! ①
- ផ្លូវដើរសុវត្ថិភាពណា ②
- ពេលចុះឡើងកាំជណ្តើរឬជណ្តើរដាក់តោងឡើង, មាន3ចំនុចទ្រទ្រង់រក្សាលំនឹងដងខ្លួនដែលជាបទបញ្ញាតិ ③



2020.3








- លំយោលមិននៅនឹងទេ ④
- ពេលធ្វើការលើដាន់នាវា ត្រូវប្រើខ្សែការពារជីវិត ឬពាក់អាវការពារជីវិត។ ហើយពេលចាំបាច់គឺទាញខ្សែពាក់សុវត្ថិភាព ⑤
- ពេលតួនាវាយោលខ្លាំង ត្រូវចងភ្ជាប់របស់ដែលអាចបំលាស់ទី ⑥

### (2) មានទំលាប់(វិន័យ)ទាំងនេះ រៀបចំ • រៀបរយ • សំអាត • ស្អាតបាត

សម្រាប់ការងារលើនាវាដែលជានិច្ចកាលមានលំយោល ហើយរលកសមុទ្របុកផ្ទប់នឹងដាន់នាវា, ដើម្បីសុវត្ថិភាព ចាំបាច់ជាពិសេសត្រូវមានទំលាប់ រៀបចំ • រៀបរយ • សំអាត។ នៅលើដាន់នាវា ប្រសិនបើគ្មានការរៀបចំ • រៀបរយ • សំអាតទេ ពេលនាវាយោល អាចជំពប់ជើងនឹងរបស់របរ, កេសដាក់គ្រឿងសមុទ្រដែលរាយប៉ាយនោះ ក៏រំកិលលើដាន់នាវា ហើយប៉ះត្រូវនាវិក។

#### 1) រៀបចំ

រៀបចំជាការបែងចែករបស់ចាំបាច់និងរបស់មិនចាំបាច់ ហើយរបស់មិនចាំបាច់គឺបោះចោល។ ស្អីក៍ដោយចេះតែបោះចោលជាមួយគ្នាក្នុងសមុទ្រទាំងអស់ ត្រូវបានហាមឃាត់ដោយច្បាប់។ ត្រូវអនុវត្តន៍តាមវិធី ណែនាំពីថ្នាក់លើ។ ⑦

#### 2) រៀបរយ

រៀបរយជាការបែងចែកប្រភេទនៃរបស់ចាំបាច់ និងដាក់នៅកន្លែងសុវត្ថិភាព និងងាយស្រួលយកពេលប្រើ។ របៀបរៀបរយ ត្រូវបានកំនត់ទៅតាមប្រភេទនាវានេសាទ ដូចនេះត្រូវអនុវត្តន៍ដោយគោរពតាមការណែនាំរបស់ថ្នាក់លើ។ របស់ធ្ងន់ របស់ងាយដួលរលំ ចាំបាច់ត្រូវចងភ្ជាប់។ ⑧

#### 3) សំអាត

សំអាតជាការធ្វើអោយស្អាត ដោយកំចាត់ប្រឡាក់ឬសម្រាមចេញ។
ដាន់នាវាពេលកំពុងនេសាទគឺប្រឡាក់ដោយឈាមកកនៃត្រី។ ដូចនេះត្រូវសំអាតទៅតាមស្ថានភាពនោះដើម្បីកុំអោយរអិលដែលបណ្តាលអោយដួល និងគ្រោះថ្នាក់ធំដូចជាការដួលធ្លាក់។ ⑨

#### 4) ស្អាតបាត

ស្អាតបាតជាការបោកគក់សំលៀកបំពាក់និងលាងដៃ, សំលាប់មេរោគឧបករណ៍ចម្អិនអាហារជាដើម និងរក្សាអនាម័យជុំវិញខ្លួន។ វាចាំបាច់សម្រាប់ការការពារទប់ស្កាត់ការកើតមានជម្ងឺ។ ⑩

#### 5) វិន័យ

ការមានទំលាប់ រៀបចំ▪រៀបរយ▪សំអាត▪ស្អាតបាត ហៅថា「វិន័យ」។ ទាំងនេះជាប្រការចាំបាច់ដែលជាមូលដ្ឋាននៃការរក្សាអនាម័យសុវត្ថិភាពក្នុងនាវា។













## 2. របស់អាចបង្ករគ្រោះថ្នាក់ និងសញ្ញាសុវត្ថិភាព

### (1) ការប៉ះពាល់ប្រើប្រាស់របស់អាចបង្ករគ្រោះថ្នាក់

នៅលើនាវាមានរបស់គ្រោះថ្នាក់(ហ្គាសសំពាធខ្ពស់, សារធាតុងាយឆេះ, សារធាតុមានជាតិពុល) ចំនួនច្រើន។ ត្រូវប្រុងប្រយ័ត្នគ្រប់គ្រាន់ក្នុងការប៉ះពាល់ប្រើប្រាស់ ដោយគោរពតាមសញ្ញាប្រកាសអាសន្ននិងថ្នាក់លើ។

1) **ហ្គាសសំពាធខ្ពស់**៖ មានដូចជាហ្គាសអាសេទីឡែនប្រើក្នុងការផ្សារដែក, សារធាតុរាវធ្វើអោយត្រជាក់ទូទឹកកក, ហ្គាសLPប្រើសម្រាប់ចម្អិនអាហារជាដើម។ វាអាចបណ្តាលអោយ ឆាបឆេះនិងផ្ទុះ, ពុលហ្គាសនិងខ្វះអុកស៊ីហ្សែន, របួសដោយត្រជាក់កកជាដើម។ មិនត្រូវបំលាស់ទីពីកន្លែងទុកដាក់ដោយគ្មានមូលហេតុ និងចាំបាច់ប្រុងប្រយ័ត្ន មិនបន្ថែមការប៉ះទង្គិចខ្លាំងដល់កំប៉ុងធុងហ្គាស ឬធ្វើអោយខូចស្នាមដល់ក្បាលវ៉ាល់ និងបំពង់ទុយោឡើយ។

2) **សារធាតុងុតឆេះ**៖ មានដូចជាប្រេងឥន្ធនៈរបស់ម៉ាស៊ីន, ប្រេងកាត, ថ្នាំលាបនិងសារធាតុរាវរំលាយ ជាដើម។ មិនត្រូវដាក់ចំហេះភ្លើងក្បែរកន្លែងទុកដាក់ឡើយ។

3) **សារធាតុពុល**៖ មានដូចជា អាស៊ីតស៊ុលផួនៃសាធាតុរាវរបស់អាគុយ, សាប៊ូកាត់កំណរក្នុងបំពង់ទឹកសមុទ្រជាដើម។ ប្រសិនបើស្រូបហ្គាសចូល ហើយអង្គធាតុរាវមានជាប់នឹងស្បែក វានឹងបង្ករអោយមានការពុលនិងរលាក។ ពេលប្រើប្រាស់ ចាំបាច់ត្រូវប្រើឧបករណ៍ការពារ(វែនតាការពារឬស្រោមដៃការពារអាស៊ិត)។ ករណីប្រើប្រាស់សាប៊ូដើម្បីបន្សាបជាតិពុល•សំលាប់មេរោគ ចាំបាច់ប្រុងប្រយ័ត្នយកអត្រាលាយបន្សាបដែលសុវត្ថិភាព។

4) **របស់គ្រោះថ្នាក់ដ៏ទៃ**៖ នៅនាវានេសាទ មានករណីរងរបួសធំៗច្រើនដូចជា ដោយសារធ្មេញត្រីឆ្លាមនិងម្ជុលបបែល, ដង្កៀបក្តាមព្រិល, និងព្រុយខ្នងត្រីម៉ាហ្គឺរ៉ុជាដើមដែលនេសាទបាន ដូចនេះត្រូវប្រុងប្រយ័ត្នកុំប៉ះពាល់។

### (2) សញ្ញាសុវត្ថិភាព

នៅលើនាវា ដើម្បីការពារទប់ស្កាត់គ្រោះថ្នាក់ដូចខាងក្រោម, មានសញ្ញាផ្សេងៗត្រូវបានបិតបង្ហាញ។ តោះមកយល់ដឹងខ្លឹមសារទាំងនោះ។

ឧទាហរណ៍បង្ហាញខាងក្រោមនេះគឺស្តង់ដារឧស្សាហកម្មជប៉ុនZ9104「សញ្ញាសុវត្ថិភាព」

| | | |
|---|---|---|
| សញ្ញាហាមឃាត់៖ ជាសញ្ញា ហាមចូល និងហាមធ្វើ។ | | |
|  |  |  |
| ហាមដាច់ខាតចំហេះភ្លើង | ហាមចូល | ហាមឆ្លងកាត់ |
| សញ្ញាអាសន្ន៖ ជាសញ្ញាជម្រុញប្រុងប្រយ័ត្ន។ | | |
|  |  |  |
| សារធាតុពុល | ប្រយ័ត្នដួលធ្លាក់ | ប្រយ័ត្នឆ្លងអគ្គិសនី |
| សញ្ញាស្ថានភាពសុវត្ថិភាព៖ ជាសញ្ញាដើម្បីបង្ហាញទីតាំងនៃច្រករត់គេចខ្លួន, ទីកន្លែងប្រអប់ថ្នាំសង្គ្រោះបឋម និងគ្រែស្នែងអ្នករបួសជាដើម។ | | |
|  |  |  |
| បង្ហាញច្រករត់គេចខ្លួន | ប្រអប់ថ្នាំសង្គ្រោះបឋម | បង្ហាញផ្លូវឆ្លងកាត់ |
| សញ្ញាបង្ការអគ្គិភ័យ៖ ជាសញ្ញាបង្ហាញកន្លែងទុកដាក់ឧបករណ៍ពន្លត់អគ្គិភ័យ។ | | |
|  |  | |
| ឧបករណ៍ពន្លត់អគ្គិភ័យ | ឆ្នុកពន្លត់អគ្គិភ័យ | |
| សញ្ញាបញ្ជា៖ ត្រូវគោរពបញ្ជានៃសញ្ញា។ | | |
|  |  |  |
| ពាក់មួកការពារ | ពាក់ម៉ាស់ | ពាក់វ៉ែនតាការពារ |
| ធ្វើសញ្ញាបង្ហាញប្រាប់អោយប្រុងប្រយ័ត្ន ចំពោះទីកន្លែងគ្រោះថ្នាក់ផ្សេងៗ ដោយលាបពណ៌ខ្មៅនិងលឿង ឬប្រើខ្សែពួរ។ | | |

### 3. ស្លៀកពាក់, ប្រើប្រាស់ឧបករណ៍ការពារត្រឹមត្រូវ







- ○ កដៃអាវដែលមិនបានបិទជិត រមូរចូលឧបករណ៍មូរសំណាញ់(Net Haulers)។ ⑪
- ○ ជាយអាវពាក់ក្រៅ រមូរចូលឧបករណ៍មូរកោណ(Cone Roller) សម្រាប់លើកដាក់សំណាញ់។ ⑫

ពេលកំពុងធ្វើការ ត្រូវស្លៀកពាក់ សំលៀកបំពាក់ការងារ, ស្បែកជើងសុវត្ថិភាពឬស្បែកជើងកៅស៊ូកវែងសុវត្ថិភាព អោយបានត្រឹមត្រូវ។ កដៃអាវ និងជុំវិញចង្កេះសំលៀកបំពាក់ ត្រូវបិទឡេវជាដើមអោយជាប់ ព្រោះវាអាចរមូរចូលម៉ាស៊ីនម៉ូទ័រវិល។ហើយត្រូវប្រើប្រាស់ឧបករណ៍ការពារសមស្របទៅតាមការងារ ដូចជាអាវការពារជីវិត, ខ្សែក្រវាត់សុវត្ថិភាព, ខ្សែការពារជីវិត និងមួកការពារជាដើម។



○ ពេលប្រើប្រាស់ខ្សែលែនយ៉ាដ(Lanyard)នៃក្រវាត់សុវត្ថិភាពដែលមានប្រដាប់ស្រូបចរន្តឆ្លង(Shock Absorber) ធ្វើជាខ្សែការពារជីវិត, ចាំបាច់ត្រូវគិតពីការលូតបន្ថែម(ចាប់ពី1m)នៃប្រដាប់ស្រូបសំណើម។

○ មួកសុវត្ថិភាព ការពាររបស់ឆាប • ធ្លាក់លើក្បាល។ ផ្ទៃរបាំង ការពារភ្នែកនិងមុខ ពីផ្លែសន្ទូចឬត្រីហោះមក។



- ○ ខោអាវភ្លៀងក៍ត្រូវបិទដៃនិងជាយអាវអោយណែនជិតដែរ។ អាវការពារជីវិតត្រូវពាក់ពីលើអាវភ្លៀង។ ⑬
- ○ ពិនិត្យមើលថាស្បែកជើងកៅស៊ូកវែងឬ ស្បែកជើងកៅស៊ូកវែងសុវត្ថិភាព បាតវាមិនរអិល។ (ស្បែកជើងកៅស៊ូកវែងសុវត្ថិភាព ដូចគ្នានឹងស្បែកជើងសុវត្ថិភាពដែរ គឺផលិតពីជ័រសាំងតេទិក ឬផលិតពីដែក ការពារចុងស្បែកជើងពីការប៉ះទង្គិច។) ⑭










○ ស្រោមដៃការពារដៃអ្នកពីរបួសនិងការប្រឡាក់ ប៉ុន្តែប្រសិនបើមិនពាក់អោយបានត្រឹមត្រូវ វាអាចរមូរចូលម៉ាស៊ីន។ ⑮

## 4. ជម្ងឺដែលត្រូវប្រុងប្រយ័ត្ននិងការការពារ

ចំពោះឧស្សាហកម្មនេសាទ ពេលខ្លះធ្វើការយប់សម្រាកថ្ងៃដែលផ្ទុយគ្នាថ្ងៃយប់ ហើយពេលខ្លះធ្វើការនិងសម្រាករយៈពេលខ្លីសារចុះឡើង ដូចនេះប្រសិនបើមិនគ្រប់គ្រងស្ថានភាពសុខភាពអោយបានហ្មត់ចត់ទេ អាចបណ្តាលអោយមានរបួសនិងជំងឺ។ ពេលធ្វើការ ត្រូវចេះគ្រប់គ្រងសុខភាពខ្លួនដោយខ្លួនឯង។ វាចាំបាច់ផងដែរ ដែលមិត្តរួមការងារជួយណែនាំអោយប្រុងប្រយ័ត្នស្ថានភាពសុខភាពទៅវិញទៅមក។

លើនាវា ទោះឈឺបន្ទាន់ នាវាមិនអាចត្រលប់ទៅផែភ្លាមបានទេ។

នៅជប៉ុន ក្រុមហ៊ុនអោយបុគ្គលិកនាយោជិកទទួលការពិនិត្យសុខភាពមួយដងក្នុងមួយឆ្នាំ។ សូមពិនិត្យសុខភាពពុំខាន។ ហើយនាវិកគួប្រើប្រាស់អោយសកម្មនូវ 「សេវាប្រឹក្សាសុខភាពឥតគិតថ្លៃ」 ដែលធ្វើជារៀងរាល់ឆ្នាំខែ9 ចំពោះសុវត្ថិភាពអនាម័យការងារនៃនាវិក ក៍ដូចជាពិនិត្យវិញ្ញាបនបត្រសុខភាពប្រចាំឆ្នាំ ក្នុងកូនសៀវភៅរបស់នាវិក។

### (1) គ្រុនក្តៅ

គ្រុនក្តៅកើតមានពេលធ្វើការយូរម៉ោងនៅបរិដ្ឋានដែលមានសីតុណ្ហភាពខ្ពស់សំណើមច្រើន ដូចជានៅជាន់នាវាដែលពន្លឺព្រះអាទិត្យប៉ះត្រូវ។

ទោះជាមិនស្រេកទឹកក្តី ចូរទទួលទានជាតិទឹកនិងជាតិអំបិល ហើយសម្រាកទៀងទាត់នៅកន្លែងរហើយ។ ⑯

ហើយបើមានរោគសញ្ញាដូចខាងក្រោម អាចជាគ្រុនក្តៅ ចាំបាច់មានវិធានការ។ ⑰

1) វិលមុខធឹងធោង, ខ្យល់ចាប់ →សម្រាកនៅកន្លែងរហើយ

2) ចង់ក្អួត, រសេះរសោះពេញខ្លួន →ទៅបន្ទប់ពេទ្យ

3) ដើរមិនត្រង់, ហៅមិនឆ្លើយ →ដឹកសង្គ្រោះបន្ទាន់







### (2) កំដៅខ្លួនចុះទាប

ពេលត្រូវហាលភ្លៀងខ្យល់ត្រជាក់ឬរលកសមុទ្រយូរ ធ្វើអោយកំដៅខ្លួនចុះទាប ដែលអាចស្លាប់ក៍មាន។ ⑱

ដងខ្លួនញ័រញាក់ ហើយចុះខ្សោយដោយភាពរងារ → ធ្វើអោយកក់ក្តៅខ្លួន, ផឹករបស់ក្តៅៗ ⑲







### (3) រោគសញ្ញាឆ្លង

<ជម្ងឺឆ្លង>ដូចជាគ្រុនផ្តាសាយធំឬរលាកក្រពះពោះវៀនដោយវីរុស ងាយនឹងរីកឆ្លងលើនាវាដែលមានកន្លែងរួមគ្នានិងចង្អៀត។ ចាំបាច់ត្រូវថែរក្សាអនាម័យកន្លែងរស់នៅ។ ដើម្បីការពារពុលអាហារ, ទឹកស្អាតត្រូវសំលាប់មេរោគ, មិនត្រូវផឹកក្រៅពីរបស់ដែលសំអាត ហើយការសំលាប់មេរោគជាតិពុលពីឧបករណ៍ចំអិនអាហារ ក៍មិនអាចខ្វះបាន។ ⑳ ㉑








### (4) ឈឺចង្កេះឬខ្នង

ការកាន់លើករបស់ធ្ងន់, ជំហរដងខ្លួនប្រឹងហួស អាចធ្វើអោយឈឺចង្កេះទៅតាមចលនា។ ពេលកាន់លើករបស់ធ្ងន់មិនត្រូវធ្វើជំហរដងខ្លួនប្រឹងហួសឡើយ។ ចូរកាន់លើកគ្នាច្រើន ជាជាងកាន់លើកម្នាក់ឯង។ ㉒








### (5) សុខភាពស្មារតី

ប្រសិនបើមានភាពតានតឹងដូចជាអារម្មណ៍ឯកោឬដាច់ដោយឡែក នៅតែបន្ត, បញ្ហាផ្លូវចិត្តដូចជា <ជង្ងឺធ្លាក់ទឹកចិត្ត> អាចនឹងវិវឌ្ឍ។ ចូរគេងនិងសម្រាកឱ្យបានគ្រប់គ្រាន់។ សូមបំបាត់ភាពតានតឹងឬស្ត្រេសប្រចាំថ្ងៃ ដោយរក្សាទំនាក់ទំនងល្អជាមួយមិត្តភ័ក្រ្ត។ ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលចិត្ត, គេងមិនលក់, ព្រួយបារម្ភឬស្ថានភាពមិនស្រួលខ្លួន សូមពិគ្រោះយោបល់យ៉ាងសកម្មជាមួយថ្នាក់លើឬមិត្តរួមការងាររបស់អ្នក។ ㉓ ㉔ ㉕

## 5. ដំណោះស្រាយពេលអាសន្ន

ប្រសិនបើលើនាវាមានអគ្គីភ័យ នាវិកទាំងអស់ត្រូវ ធ្វើសកម្មភាពពន្លត់អគ្គីភ័យ, ការពារទឹកពេលទឹកលិចចូល, ជួយសង្គ្រោះមនុស្សធ្លាក់ចូលសមុទ្រ ឬដួលដោយសារកង្វះអុកស៊ីសែននៅក្នុងកន្លែងស្តុកត្រីជាដើម។ ហើយប្រសិនជាអកុសលនាវាហៀបនឹងលិច  អ្នករាល់គ្នាត្រូវតែចាកចេញពីនាវាដោយក្បូនសង្គ្រោះជីវិតជាដើម និងសហការគ្នា ហើយរង់ចាំការជួយសង្គ្រោះ។

លើនាវា មានបែងចែកតួនាទីរបស់នាវិកម្នាក់ៗដើម្បីប្រុងប្រៀបសម្រាប់ស្ថានភាពអាសន្នទាំងនេះ។ បន្ទាប់ពីឡើងនាវា ដំបូងត្រូវតែបញ្ជាក់ពីតួនាទីដែលបានកំណត់ឱ្យខ្លួន នៅក្នុងតារាងទីតាំងបន្ទាន់។ សំខាន់ណាស់ក្នុងការសួរថ្នាក់លើហើយយល់ពីអ្វីដែលមិនយល់។ ត្រូវចងចាំសញ្ញាប្រាប់គ្នា និងភ្លើងសញ្ញាក្នុងករណីអាសន្នដូចជាអគ្គីភ័យជាដើមផងដែរ។

ហើយត្រូវមើលបញ្ជាក់ជាមុននូវសកម្មភាពដែលគួរធ្វើដំបូងគេ ពេលរកឃើញអគ្គីភ័យឬការដួលធ្លាក់ចូលក្នុងសមុទ្រ។ ក្នុងករណីណាក៏ដោយ សម្រាប់អ្នករកឃើញទីមួយ, អ្វីដែលត្រូវធ្វើដំបូងគេគឺ“ផ្តល់ដំណឹង” ដល់នាវិកដ៏ទៃទៀត ដូច្នេះពួកគេមិនត្រូវលោតចូលផ្សេងតែម្នាក់ឯងដើម្បីពន្លត់អគ្គីភ័យ ឬលោតចូលជួយអ្នកដួលធ្លាក់ចូលក្នុងសមុទ្រតែម្នាក់ឯងជាដើមឡើយ។







- 「ប្រយ័ត្នប្រយែង!」㉖
- 「មានមនុស្សធ្លាក់!」ស្រែកបណ្ដើរ បោះរបស់អណ្ដែតដូចជាប្រអប់ឈើចូលបន្ដបន្ទាប់។ ㉗







- ជួសជុសបន្ទាន់សិន ដោយមូររុំខ្សែព្ឫរជុំវិញមុខបែកធ្លាយនៅលើបំពង់ទឹកសមុទ្រ។ ㉘
- 「ភ្លើងឆេះ!!」ការបាញ់ពន្លត់អគ្គីភ័យបឋម គឺបាញ់ខិតជិតប្រភពភ្លើងពីខ្យល់។ ㉙







- ជំនួយសង្គ្រោះដាច់ខាតនឹងមក! ㉚
- ជំនួយសង្គ្រោះមកដល់ហើយ! ㉛




**ស្ថិតិប្រចាំឆ្នាំ2014～2017 នៃរបាយការណ៍មាត្រា111 ច្បាប់ស្តីពីបុគ្គលិកកម្មករនាវា**

## 6. វិធានការសុវត្ថិភាពចំពោះការងារលើនាវា

គ្រោះថ្នាក់កើតមានលើនាវានេសាទ ភាគច្រើនកើតមានពេលកំពុងធ្វើការ។

**1) រមូរចូល, គៀបជាប់**

លើនាវាមានម៉ាស៊ីនជាច្រើន ដែលបញ្ចេញលទ្ធផលធំៗដូចជា ឧបករណ៍នេសាទនិងឧបករណ៍ចងនាវាកុំអោយរសាត់។ ខ្លះមានគម្របឬរបស់ការពារការប៉ះ ប៉ុន្តែវាមិនមានឧបករណ៍សុវត្ថិភាពដូចទ្វារជណ្តើរយន្តដែលដឹងវត្ថុចំលែក ហើយឈប់ដោយស្វ័យប្រវត្តិទេ។ ទោះបីជាមានប៊ូតុងបញ្ឈប់បន្ទាន់ក៏ដោយ ក៏វានឹងមិនបញ្ឈប់ដែរលុះត្រាតែមានអ្នកណាចុចវា។

គ្រោះថ្នាក់ជាច្រើនបានកើតឡើង ដូចជាការរមូរចូលក្នុងនិងគៀបជាប់ឧបករណ៍ស្ទូច・សំណាញ់នេសាទ ហើយមួយផ្នែកឬរាងកាយទាំងមូលត្រូវបានមួលនិងកំទេច។

**ករណីគ្រោះថ្នាក់ 1៖** ក្នុងការងារលើកដាក់សំណាញ់ នៅពេលមូរចងសំណាញ់ដោយឧបករណ៍រុំពាក់ខ្សែ ហើយស្ទូចលើក, ដៃឆ្វេងត្រូវបានរមូរចូលទាំងអញ្ចឹង ពេលលើកដោយឧបករណ៍ទាញមូរខ្សែ។ ការងារមូរចងសំណាញ់ដោយឧបករណ៍រុំពាក់ខ្សែត្រូវបានធ្វើដោយមនុស្សពីរនាក់។ ㉜
**មូលហេតុ៖** មិនបានប្រាប់គ្នាទៅវិញទៅមកអោយប្រុងប្រយ័ត្នចំពោះសកម្មភាពពេលកំពុងធ្វើការ។ បានធ្វើសញ្ញាប្រាប់អោយមូរលើក ដោយមិនបានពិនិត្យបញ្ជាក់ស្ថានភាព។
**វិធានការការពារទប់ស្កាត់៖** ពេលធ្វើការងារដោយនាវិកច្រើនគ្នា, ទោះពេលប្រញាប់ ត្រូវប្រាប់គ្នាទៅវិញទៅមកអោយប្រុងប្រយ័ត្ន ពិនិត្យបញ្ជាក់ស្ថានភាពរួចចាំធ្វើសកម្មភាពបន្ទាប់។







**ករណីគ្រោះថ្នាក់ 2៖** ក្នុងពេលធ្វើការលើកដាក់សំណាញ់ដោយប្រើឧបករណ៍មូរសំណាញ់(Net Haulers), នាវាឃ្លីងឃ្លោងខ្លាំងដោយសារព្យុះភ្លៀង ហើយបាត់បង់តុល្យភាពដងខ្លួន, ដៃអាវភ្លៀងត្រូវបានកៀបជាប់ ហើយដៃឆ្វេងឬដើមដៃត្រូវបានកៀបនឹងឧបករណ៍មូរសំណាញ់។ ㉝
**មូលហេតុ៖** បាត់បង់តុល្យភាពដងខ្លួន។ ខិតជិតឧបករណ៍មូរពេក។ បញ្ឈប់ឧបករណ៍មូរមិនទាន់។
**វិធានការការពារទប់ស្កាត់៖** សម្រាប់ការងារពេលព្យុះភ្លៀង ត្រូវរក្សាជំហរកុំអោយបាត់បង់តុល្យភាពដងខ្លួន និងមិនចូលជិតជ្រុលម៉ាស៊ីនមូររិលឡើយ។ ចាំបាច់ប្រុងប្រៀប ដាក់អ្នកឃ្លាំមើល និងបញ្ឈប់បន្ទាន់។

### (2) ប្រតិកម្មតបចលនា • ចលនាហួសកម្រិត

វាអាចមានគ្រោះថ្នាក់ដូចជាពត់ចង្កេះដោយសារលើករបស់ធ្ងន់, ឈើ រមួល គ្រេចសាច់ដុំ ដោយសារជំហរចលនាដងខ្លួនហួសកម្រិត។ ក្រៅពីការងារនេសាទ, វាក៏កើតមានញឹកញាប់ដែរ ពេលប្រើប្រាស់ របស់គ្រងចាប់ត្រី, សន្ទូចត្រី និងសំណាញ់នេសាទផងដែរ។

**ករណីគ្រោះថ្នាក់ 1៖** ពេលលើកឡើងកន្ត្រងដាក់ត្រីចាប់បាន ប្រហែល30kg ហើយរៀបនឹងដាក់តាមមាត់ច្រកម៉ាស៊ីនបែងចែករើស, លំយោលនាវាធ្វើអោយបាត់បង់តុល្យភាព ហើយពត់ដៃស្តាំ។ ㉞
**មូលហេតុ៖** កាន់លើករបស់ធ្ងន់តែម្នាក់ឯង។ មិនអាចរក្សាតុល្យភាពដងខ្លួនដោយសារលំយោលនាវា។
**វិធានការការពារទប់ស្កាត់៖** ចូរកុំភ្លេចថារបស់មិនពិបាកកាន់លើកនៅលើគោក ខុសគ្នានៅលើនាវា, ពេលលើកដាក់របស់ធ្ងន់មិនត្រូវធ្វើម្នាក់ឯងទេគឺធ្វើពីរនាក់ឡើង ហើយប្រុងប្រយ័ត្នចំពោះស្ថានភាពជំហរជើងនិងលំយោលនាវា។ (ត្រូវគិតថាប្រសិនពេលនោះខំហួសកម្រិតហើយត្រូវរបួស ចុងក្រោយបានត្រឹមបន្ថែមបន្ទុកធំដល់នាវិកផ្សេងទៀត, ដូចនេះការហ៊ានសុំជំនួយពិតជាសំខាន់ផងដែរ។)

**ករណីគ្រោះថ្នាក់ 2៖** នៅកន្លែងឈរស្ទូចពេលកំពុងស្ទូចចូល ត្រីដែលជាប់បានគ្រវីគ្រវាត់ របូតពីផ្លែសន្ទូច អ្នកស្ទូចរៀបនឹងដួលទៅក្រោយ ខំទប់ជំហរដែរតែគ្រេចចង្កេះខាងស្តាំ។ ㉟
**មូលហេតុ៖** ពេលស្ទូចលើកត្រីធូណាស្គីព្យាក(ត្រីកាត្សឺអុ) មិនបានគិតជាមុនថារបូតផ្លែសន្ទូច ហើយមិនបានប្រុងប្រៀបជំហរខ្លួនតាមនោះ។
**វិធានការការពារទប់ស្កាត់៖** ពេលកំពុងស្ទូចចូល ត្រីអាចគ្រវីគ្រវាត់របូតពីផ្លែសន្ទូច និងខ្សែសន្ទូចអាចដាច់។ ចាំបាច់ធ្វើជំហរទប់ទល់ក្នុងពេលនោះផងដែរ។ ជាធម្មតា ដាក់កជើងទាំងពីរក្រោមបំពង់បាញ់ទឹកដើម្បីធ្វើអោយជាប់ជំហរជើង។









2020.3

### (3) ដួលរលំ, ដួលធ្លាក់, ធ្លាក់ចុះ

ដួលរលំជាគ្រោះថ្នាក់កើតឡើងដោយសារ ជំពប់ រអិលដួលនៅលើជាន់នាវាជាដើម។ បុកទង្គិចខ្លាំងទៅនឹងកម្រាលជាន់ឬរបស់គ្រោង ត្រូវរបួសធ្ងន់ ហើយករណីខ្លះក៏មានករណីដល់ស្លាប់បាត់បង់ជីវិត ។
ហើយការធ្លាក់ពេលកំពុងប៉ះជាន់កាំជណ្តើរឬជណ្តើរលូតដាក់គោងជាដើម ហៅថា「ដួលធ្លាក់」, និងដងខ្លួនធ្លាក់ពីលើអាកាសមកទាំងស្រុងហៅថា「ធ្លាក់ចុះ」។

**ករណីគ្រោះថ្នាក់៖** ពេលកំពុងលើកដាក់គ្រឿងបរិភោគ បានរអិលជើង ហើយបានធ្លាក់ពីជាន់នាវាមកកន្លែងស្តុកត្រី ហើយបានបុកជង្គង់ខាងស្តាំខ្លាំង។ ㊱

**មូលហេតុ៖** ពេលកំពុងបោះយុថ្កាចុះឈប់, ពុំមានលំយោលនាវាទេ តែមិនបានប្រុងប្រយ័ត្នអោយមែនទែនចំពោះជំហរជើង។

**វិធានការការពារទប់ស្កាត់៖** នៅជាន់នៃនាវានេសាទ, មានផ្នែកមាត់បើកនៃអាងស្តុកត្រី និងឧបករណ៍ស្ទូចត្រីនៅកន្លែងចង្អៀត និងកន្លែងលយចេញ ដូចនេះទោះពេលនាវាមិនយោលក្តី ចាំបាច់ប្រុងប្រយ័ត្នអោយបានគ្រប់គ្រាន់។ ត្រូវជៀសវាងការអោបលើករបស់ដែលមើលមិនឃើញខាងមុខ។




### 4) ការដួលធ្លាក់ក្នុងសមុទ្រ

វាងាយកើតមាន ពេលជំពប់, គ្រលែងតាមលំយោលនាវា, រមូរចូលឧបករណ៍ស្ទូចត្រី • សំណាញ់ត្រី, ហូរតាមរលកជាដើម ហើយជាគ្រោះថ្នាក់ដែលមានអត្រាស្លាប់ខ្ពស់។
វាកើតឡើងជាចម្បងពេលកំពុងនេសាទ ប៉ុន្តែវាក៏កើតឡើងផងដែរនៅពេលស្រវឹងស្រាបាញ់នោមកៀននាវា ឬពេលចុះឡើងនាវានិងដីគោក។ ក៏មានករណីជាច្រើនទៀតដែលមូលហេតុមិនច្បាស់លាស់ព្រោះមិនមានសាក្សីបានឃើញ។

**ករណីគ្រោះថ្នាក់ 1៖** ពេលកំពុងបោះសំណាញ់ គេបញ្ចេញបន្តបន្ទាប់នូវឧបករណ៍នេសាទដូចជា របស់អណ្តែត, ខ្សែពួរ និងសំណាញ់ជាដើម នៅពេលដែលខ្សែចុងក្រោយត្រូវបានបញ្ចេញ, ក៏ធ្លាក់បាត់ខ្លួនក្នុងសមុទ្រជាមួយនឹងខ្សែពួរពីស្លីបវេឬផ្លូវរអិល។ ㊲

**មូលហេតុ៖** ធ្វើការកៀកជាប់នឹងខ្សែពួរដែលបញ្ចេញពីស្លីបវេ។ នាវិកមិនបានប្រាប់គ្នាអោយប្រុងប្រយ័ត្នទៅវិញទៅមកនូវជំហរធ្វើការនិងទីតាំងឈរ។

**វិធានការការពារទប់ស្កាត់៖** ស្លីបវេគឺងាយរអិល ដូចនេះត្រូវប្រុងប្រយ័ត្នជំហរជើង, ត្រូវពាក់ស្បែកជើងសុវត្ថិភាពដែលទប់កុំអោយរអិល, ហើយមិនត្រូវកន្ទែកជើងដើរឆ្លងខ្សែពួរ ឬដាក់ជើងក្នុងកង និងប្រុងប្រយ័ត្នកន្លែងឈរផងដែរ។ វាសំខាន់ណាស់ដែលនាវិកផ្តល់សញ្ញាប្រាប់ការងារច្បាស់លាស់ ហើយនាវិកឃ្លាំមើលគ្នា, ប្រាប់គ្នា និងប្រុងប្រយ័ត្នទីតាំងឈរ។

**ករណីគ្រោះថ្នាក់ 2៖** ពេលនាវាកំពុងបើកបរដោយបានបញ្ចប់ការលើកដាក់សំណាញ់ នាវិកដែលបានធ្វើការរៀបចំសំណាញ់លើជាន់នាវាផ្នែកខាងក្រោយ បានបាត់បង់តុល្យភាពដងខ្លួន ហើយធ្លាក់ចូលសមុទ្រ និងបានបាត់ខ្លួន។ ㊳ ㊴

**មូលហេតុ៖** បានធ្វើការតែម្នាក់ឯងនៅលើសំណាញ់ដែលមានកន្លែងដាក់ជើងអន់។ នៅពេលបាត់បង់តុល្យភាពដងខ្លួនដោយសារលំយោលនៃតួនាវា, អត់មានរបស់កាន់ដើម្បីទប់ដងខ្លួនដូចជាបង្កាន់ដៃជាដើមឡើយ។

**វិធានការការពារទប់ស្កាត់៖** នៅលើសំណាញ់នេសាទដែលមានកន្លែងដាក់ជើងអន់, ត្រូវប្រុងប្រយ័ត្នជាពិសេសចំពោះជំហរជើង ហើយរក្សារបស់ដែលទប់ដងខ្លួននៅពេលបាត់បង់តុល្យភាពអោយជាប់ប្រចាំ។ អនុលោមតាមច្បាប់ នៅពេលធ្វើការលើជាន់នាវា ត្រូវប្រើប្រាស់អាវការពារជីវិត ឬធ្វើការចាប់ពីពីរនាក់ឡើង ហើយគោរពយ៉ាងម៉ឺងម៉ាត់ចំពោះការដាក់អ្នកឃ្លាំមើល។







# II ការងារចិញ្ចឹមជលផល

## 1. ការងារចិញ្ចឹមជលផល

សម្រាប់អ្នកធ្វើការចិញ្ចឹមជលផល ចាំបាច់ប្រុងប្រយ័ត្នពេលត្រូវធ្វើការដូចគ្នានឹងការងារលើនាវាផងដែរ។ សូមអាន ⇒ Ⅰ. 3, 4

## 2. វិធានការសុវត្ថិភាពនៃការងារចិញ្ចឹមជលផល

**ករណីគ្រោះថ្នាក់ 1៖** នៅកន្លែងលាងអយស្ទ័រ កម្រាលជាន់សើម តែដោយប្រញាប់ទើបរត់ ក៏រអិលដួលបាក់កដៃ។ ㊵
**មូលហេតុ៖** កម្រាលជាន់សើម ហើយរត់។
**វិធានការការពារទប់ស្កាត់៖** កម្រាលជាន់សើម ងាយរអិល។ ត្រូវពាក់ស្បែកជើងមិនងាយរអិល។ ដើរ មិនត្រូវរត់។

**ករណីគ្រោះថ្នាក់ 2៖** ពេលកំពុងប្រើខ្សែពាននាំឬខនវេយ័រសម្រាប់ដឹកជញ្ជូនប្រភេទលៀសគ្រំ មានកំទេចជាប់ស្ទះនៅផ្នែកបង្វិល ហើយពេលយកចេញ ដៃកៀបជាប់។ ㊶
**មូលហេតុ៖** យកកំទេចចេញដោយមិនបានបញ្ឈប់ម៉ាស៊ីនជាមុន។
**វិធានការការពារទប់ស្កាត់៖** ពេលយកកំទេចជាប់ចេញពីម៉ាស៊ីន ឬពេលសំអាត ដាច់ខាតត្រូវបញ្ឈប់ម៉ាស៊ីន។




